00304210

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 10 / 04 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

E1/9

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 10 / 04 / 2009
ម៉ោង (Time/Heure): 10:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

**<u>កំណត់ហេតុជាលាយលក្ខណ៍អក្សរ</u>**
**<u>នៃដំណើរការនីតិវិធីនៃសវនាការលើអង្គសេចក្តី</u>**
**<u>ក្នុងសំណុំរឿងលេខ ០០១</u>**

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

ថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០៩-ថ្ងៃទីប្រាំ

**សាធារណៈ**

រៀបចំដោយ: **សែ គុលវុឌ្ឍី** និង **Natacha Wexels-Riser**

| |
|---|
| <u>កំណត់ហេតុអ្នកចូលរួម</u> |
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម ធូ មណី |
| ចៅក្រមបម្រុង៖ ចៅក្រម យូរ ឧត្តរា (បម្រុង) និង ចៅក្រម Claudia FENZ (បម្រុង) |
| ក្រឡាបញ្ជី៖ លោក លឹម ស៊ុយហុង, លោក Crippa MATTEO,លោកស្រី សែ កុលវុឌ្ឍី, កញ្ញា Natacha Wexels-Riser |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោកស្រី ជាលាង, លោក Robert Petit, លោក [illegible] លោក ប៉ាក ចន្ទលីណូ,ពេជ្រ សម្បត្តិ, លោក Alexander Bates,លោក Jurgen Assmann |

| ជនជាប់ចោទ៖ កាំង ហ្គេកអ៊ាវ ហៅ ឌុច |
|---|
| មេធាវីជនជាប់ចោទ៖ លោក Francois Roux,លោកស្រី Heleyn Unac,លោក ចាន់ រ៉ាវុធ, កញ្ញា Lucile Nattiez, កញ្ញា Virginie Charpentier,លោកស្រី Marie-Paule Canizares។ |
| មេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖លោក គង់ ពិសី,លោក យុង ផានិត, កញ្ញា Silke Studzinsky , លោក គីម ម៉េងឃី, កញ្ញា ទី ស្រីនណា, លោក Alain Werner,លោក Philippe Canonne |
| មន្ត្រីតុលាការ/អង្គភាពគ្រប់គ្រងតុលាការ៖ លោក ខូវ កែវរតនៈ |
| ផ្នែកផ្សេងៗ៖ លោក Scott Bywater, កញ្ញា Julie Masse, លោក Pierre Cozette, កញ្ញា Marivonne Moussounda Maniacky |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃ ទី ០៧ ខែមេសា ឆ្នាំ ២០០៩ ព្រឹក | ចាប់ផ្តើមម៉ោង៖ ៩.០៥ | បញ្ចប់ម៉ោង៖ ១៦.៣៥ |
| សម្រាកព្រឹក | ចាប់ផ្តើមម៉ោង៖១០.៣៥ | បញ្ចប់ម៉ោង៖ ១០.៥៥ |
| សម្រាក អាហារថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖១២.០៥ | បញ្ចប់ម៉ោង៖១៣.៣៥ |
| សម្រាកល្ងាច | ចាប់ផ្តើមម៉ោង៖ ១៤.៥០ | បញ្ចប់ម៉ោង៖ ១៥.១០ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | **៥ ម៉ោង ២០ នាទី** |

| **កិច្ចដំណើរការនីតិវិធី៖** | | | |
|---|---|---|---|
| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
| វត្តមានរបស់សាក្សីក្នុងអំឡុងពេលសវនាការ | មេធាវីការពារ | ៩.១០ | ៩.១៨ |
| ការសួរសំណួរទៅជនជាប់ចោទទាក់ទងនឹងអង្គហេតុម១៣ដោយអង្គជំនុំជម្រះ | អង្គជំនុំជម្រះ | ៩.២០ | |
| ភាពមិនអាចទទួលយកបាននូវឯកសារបទសម្ភាសន៍ជាមួយ ហាម អ៊ិន របស់មជ្ឈមណ្ឌលឯកសារកម្ពុជា (ឯកសារលេខ D59 ឧបសម្ព័ន្ធ៤) និងបទសម្ភាសន៍ជាមួយនិង អ៊ឹម វន របស់មជ្ឈមណ្ឌលឯកសារកម្ពុជា (ឯកសារលេខ D59 ឧប | មេធាវីការពារ | ១១.៤៥ | ១១.៥០ |

| | | | |
|---|---|---|---|
| សម្ព័ន្ធ១២) | | | |
| ការសួរសំណួរទៅជនជាប់ចោទទាក់ទងនឹងអង្គហេតុម១៣ ដោយសហព្រះរាជអាជ្ញា | សហព្រះរាជអាជ្ញា | ១៤.១០ | ១៥.៤០ |
| ការសួរសំណួរទៅជនជាប់ចោទទាក់ទងនឹងអង្គហេតុម១៣ដោយមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី | មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុមទី១,២ និង ៣ | ១៥.៤០ | ១៦.៣០ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធី៖</u>**

**-វត្តមានរបស់សាក្សីនៅក្នុងដំណើរការនីតិវិធី៖**

មេធាវីការពារបានស្នើទៅអង្គជំនុំជម្រះឱ្យត្រួតពិនិត្យប្រសិនបើមានសាក្សីអង្គុយនៅក្នុងបន្ទប់សវនាការ នឹងបានរំលឹកថាសាក្សីទាំងអស់នោះមិនអាចចូលរួមស្តាប់សវនាការបានទេ។

អង្គជំនុំជម្រះបានរំលឹកឡើងវិញដោយអនុលោមតាមវិធានផ្ទៃក្នុងថាសាក្សីមិនអាចចូលរួមស្តាប់សវនាការមុនពេលពួកគេផ្តល់សក្ខីកម្មបានទេ ហើយបានស្នើឱ្យសាក្សីដែលបានចូលរួមនៅក្នុងសវនាការឱ្យចាកចេញពីបន្ទប់សវនាការ និងបង្គាប់ឱ្យផ្នែករដ្ឋបាលដែលពាក់ព័ន្ធធានាមិនឱ្យមានវត្តមានសាក្សីនៅក្នុង បន្ទប់សវនាការមុនពេលដែលពួកគេផ្តល់សក្ខីកម្មឡើយ។

**-ការសួរសំណួរទៅជនជាប់ចោទទាក់ទងនឹងអង្គហេតុម១៣ដោយអង្គជំនុំជម្រះ៖**

អង្គជំនុំជម្រះបានបន្តសួរសំណួរទៅជនជាប់ចោទទាក់ទងនឹងអង្គហេតុម១៣ ដែលរួមមាន៖

- លក្ខខណ្ឌនៃការឃុំខ្លួន
- សំណួរទាក់ទងនឹងអ្នកជាប់ឃុំ
- ការសម្លាប់អ្នកជាប់ឃុំ
- ការបញ្ចប់ និងការបិទមន្ទីរម១៣
- របៀបនៃការធ្វើទារុណកម្ម

អង្គជំនុំជម្រះបានយកឯកសារដែលមានចំណងជើងថា "បទសម្ភាសន៍ជាមួយ ហាម អ៊ិន"(ឯកសារលេខ D59 ឧបសម្ព័ន្ធ៤) និងបានអានបន្ថែមទាក់ទងនឹងលេខ ERN 00289745 និង 00289749 ជាភាសាអង់គ្លេស និងលេខ ERN 00295087 និង 00295091 ជាភាសាបារាំង)។

មេធាវីការពារបានជំទាស់ ក្នុងការប្រើប្រាស់ឯកសារនេះ និងឯកសារដែលមានចំណងជើងថា "បទសម្ភាសន៍

ជាមួយ អ៊ុម វន" (ឯកសារ លេខ D59 ឧបសម្ព័ន្ធ១២) ដោយសំអាងថាឯកសារទាំងនេះមិនមែនជាឯកសាររបស់តុលាការ ហើយថាបទសម្ភាសន៍ត្រូវបានធ្វើឡើងដោយអង្គការក្រៅរដ្ឋាភិបាលមួយ មិនមែនដោយចៅក្រមនោះទេ ហើយអត្តសញ្ញាណរបស់អ្នកបកប្រែនោះមិនបានដឹងថាគាត់បានស្បថរួចហើយនោះទេ។

សហព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថាឯកសារទាំងនេះគឺមាននៅក្នុងសំណុំរឿង ហើយរាល់ភស្តុតាងទាំងអស់គឺអាចទទួលយកបាន។ ពួកគេបានស្នើថា ប្រសិនបើអត្ថបទត្រូវបានអាននៅក្នុងពេលសវនាការ គួរតែអានជាភាសាខ្មែរ ដែលជាភាសាដើមនៃឯកសារនោះ ។

អង្គជំនុំជម្រះចង្អុលបង្ហាញថាឯកសារទាំងនេះមិនត្រូវប្រើនៅក្នុងពេលនេះទេ ហើយសេចក្តីសម្រេចទៅលើភាពអាចទទួលយកបាននៃឯកសារទាំងនេះនឹងចេញនៅពេលវេលាសមស្រប។ អង្គជំនុំជម្រះបានស្នើទៅភាគីទាំងអស់មិនឱ្យយោងទៅលើឯកសារទាំងនេះនោះទេ។

អង្គជំនុំជម្រះបានអាននូវឯកសារបន្ថែមពី "កំណត់ហេតុស្តួរចម្លើយខុច ដោយសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ២៩ មេសា ២០០៨" (ឯកសារលេខ D70 លេខERN 00185482 ជាភាសាបារាំង និង 00185475 ជាភាសាអង់គ្លេស ហើយនិង 00185467 ជាភាសាខ្មែរ)។

**-ការសួរសំណួរទៅជនជាប់ចោទដោយសហព្រះរាជអាជ្ញា៖**

សហព្រះរាជអាជ្ញាបានសួរសំណួរទៅជនជាប់ចោទទាក់ទងនឹងម១៣

**-ការសួរសំណួរទៅជនជាប់ចោទដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖**

មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១ និងក្រុមទី២ បានសួរសំណួរទៅជនជាប់ចោទទាក់ទងនឹងម១៣។

អង្គជំនុំជម្រះបានសួរទៅមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដែលមិនទាន់បានសួរដោយបានកំណត់នូវរយៈពេល ២០នាទី សម្រាប់ការសួរសំណួររបស់ពួកគេ។

មេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី២ បានជំទាស់ចំពោះការកំណត់នូវពេលវេលាក្នុងការសួរជនជាប់ចោទនិងបានស្នើក្នុងការសួរសំណួរទាំងអស់ក្នុងពេលជាមួយគ្នា។

មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី៣ បានសួរសំណួរទៅជនជាប់ចោទទាក់ទងនឹងម១៣ ។

**កំណត់ហេតុនៃដំណើរការនីតិវិធី វិធាន ៨៧៖**

| លេខយោង | ឈ្មោះ/សេចក្តីអត្ថាធិប្បាយ | ផ្សេងៗ |
|---|---|---|

| | | |
|---|---|---|
| E3/3 | កំណត់ហេតុនៃការសួរចម្លើយខុច ដោយសហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០០៨។ | D70 |

| |
|---|
| <u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u> |
| ១-អង្គជំនុំជម្រះបានរំលឹកឡើងវិញអនុលោមតាមវិធានផ្ទៃក្នុង សាក្សីមិនអាចចូលរួមស្តាប់សវនាការនៅមុនពេលពួកគេផ្តល់សក្ខីកម្មនោះទេ។ អង្គជំនុំជម្រះបានបង្គាប់ឱ្យសាក្សីដែលបានចូលរួមក្នុងសវនាការឱ្យចាកចេញពីបន្ទប់សវនាការ និងបង្គាប់ឱ្យផ្នែករដ្ឋបាលដែលពាក់ព័ន្ធធានា មិនឱ្យមានវត្តមានសាក្សីនៅក្នុងបន្ទប់សវនាការមុនពេលពួកគេផ្តល់សក្ខីកម្មឡើយ ។<br>២-ដីកាបង្គាប់ឱ្យនាំជនជាប់ចោទត្រឡប់ទៅមន្ទីរឃុំឃាំង និងនាំគាត់មកវិញនៅថ្ងៃទី ០៨ ខែមេសា ឆ្នាំ ២០០៩ ។ |

| |
|---|
| <u>ដីកាសម្រាប់ការលើកពេលសវនាការ</u> |
| ការពន្យាពេលសវនាការ៖ សវនាការនឹងបន្តទៅថ្ងៃស្អែក ទី ០៨ ខែមេសា ឆ្នាំ ២០០៩ វេលាម៉ោង ៩.០០ព្រឹក ។ |

ភ្នំពេញ, ថ្ងៃទី ០ ខែមេសា ឆ្នាំ ២០០៩

| | |
|---|---|
| ក្រឡាបញ្ជី | ក្រឡាបញ្ជី |
| **សែ គុល ទុម្សី** | **Natacha Wexels-Riser** |